**BMI00201**

**សម្ភាសន៍ជាមួយ អ៊ុល ភាព ភេទប្រុស អាយុ៦២ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ធ្វើស្រែ**

**មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ**

**សព្វថ្ងៃរស់នៅភូមិប៉ុស្តិចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ**

**ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ពៅ ដារ៉ាវ និង ឡុង ដានី**

**០០:៣៤:៣៦**

**២៤ទំព័រ**

ដារ៉ា : ពូខ្ញុំឈ្មោះដារ៉ា ហើយនេះឈ្មោះ ដានី ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចង់សួរនាំពូបន្តិចបន្តួចទាក់ទងទៅនឹងការដែលពូបានផ្តល់ពត៌មានទៅឲ្យតុលាការអីចឹងពូ ពួកខ្ញុំចង់ឲ្យពូរៀបរាប់សាច់រឿងពីដំបូងមក តើពីដំបូងមកពេលដែលតុលាការជួបពូ ហើយដល់ពេលគេបានត្រឡប់ទៅវិញអីចឹង តើគេបាននិយាយអីខ្លះៗអីចឹងពូ? ពីដំបូង បន្ទុសហ្នឹងគឺថាតុលាការមកដល់កន្លែងផ្ទះពូហ្នឹងមកតាមរបៀបយ៉ាងម៉េច?

ភាព : បាទ!ដែលតុលាការមកនេះគេមកសួររកឈ្មោះ ផាត ៗ ដល់ផាត ទៅសួរខាងកើតនោះគេចន្ទុលមកផ្ទះខ្ញុំនេះ ប្រពន្ធខ្ញុំនេះឈ្មោះ ផាត ដល់មកសួរទៅក៏មកសួរប៉ះប្រពន្ធខ្ញុំៗប្រាប់ដំណើរដើមទងថា ខ្ញុំមិនមែនឈ្មោះ ផាតទេ ខ្ញុំឈ្មោះផាក គាត់ក៏រៀបចេញទៅវិញហើយ ៗ ខ្ញុំនេះមកពីចងគោ ដល់ខ្ញុំមកពីចងគោថាចេះនេះអ្នកណាមក....ដល់មកភ័យតុលាការគេសួរ ៗ ដល់ខ្ញុំសួរយាយថា គេមកមានរឿងអី ហ៊ីគេមកប្រាប់គ្នារឿងសម័យពឆ្នាំសួរពីរឿងប្រវត្តិយាយចែម ហ៊ី!យាយចែម អ្នកណាមិនស្គាល់គាត់ខ្ញុំក៏ឆ្លើយចេះទៅ ៗ ខ្ញុំធ្លាប់ព្រៃតែឈ្មោះយាយចែមហ្នឹងបានគេអ្នកយកពត៌មានអ៊ូ!នេះគាត់ស្គាល់យាយចែមដែរ ៗ បានជាគាត់យកគ្រឿងយកក្រោយកមកថតខ្ញុំ ខ្ញុំក៏ឆ្លើយតាមប្រវត្តិខ្ញុំដែលយាយប្រាប់ប្អូនឯងមិញហ្នឹងឯងប៉ុណ្ណោះឯង ៗ

ដារ៉ា : អីចឹងពេលដែលមកហ្នឹងមានប៉ូលិសមានអីមកដែរ?

ភាព : បាទ!មានប៉ូលិសមកម្នាក់ ប៉ូលិសស្រុក ៗ

ដារ៉ា ៖ ប៉ូលីសស្រុកអី?

ភាព ៖ ស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ មកហ្នឹងមានមកតាមឃុំអីដែលពូ?

ភាព ៖ គេមកគេចូលលោកហ៊ុយមុន ចូលហ៊ុយហើយបានគេសួររកឈ្មោះ ដាត។ ហើយគេប្រាប់មករកប្រពន្ធខ្ញុំនេះ ប្រពន្ធខ្ញុំ ដាក ប៉ុន្តែក៏មិនចាប់អារម្មណ៍ទេ ទទួលចេញមកនេះខ្ញុំមកចង់គោនេះបានទំនាក់ទំនងខ្ញុំៗថា យាយថែម អ្នកណាមិនស្គាល់សម័យ៣ឆ្នាំ ។ បានជាទាក់ទងមកដល់ខ្ញុំ បានជាសួរមកដល់ខ្ញុំនេះស្រាវជ្រាវពីខ្ញុំនេះណា បានខ្ញុំថាខ្ញុំស្គាល់នោះ ។ ខ្ញុំពុំតែឈ្មោះដូចប្រាប់ប្អូនអីចឹងឯង ធ្លាប់ពុំតែឈ្មោះទេ រូបរាងខ្ញុំមិនដែលឃើញទេ ពីព្រោះខ្ញុំរស់នៅក្នុងទឹកដីព្រះនេត្រព្រះនេះហើយគាត់រស់នៅឯភ្នំលាបឯនោះ ។

ដារ៉ា ៖ តើហេតុអីបានខាងតុលាការគេដឹងថាឈ្មោះ ដាត។ នៅចុងខាង?

ភាព ៖ មិនដឹងយ៉ាងម៉េចទេ ខ្ញុំក៏មិនដឹងដែរ មិនចឹងថាគេដឹងមកពីណាទេ ខ្ញុំក៏មិនដឹង ។

ដារ៉ា ៖ ដល់ពេលចូលមកឃុំព្រះនេត្រព្រះនេះតុលាការគេមក ដោយមានប៉ូលីសមក?

ភាព ៖ បាទ!ប៉ូលីសមួយនាក់ ។

ដារ៉ា ៖ ប៉ូលីសស្រុក?

ភាព ៖ បាទ!ប៉ូលីសស្រុក ។

ដារ៉ា ៖ ប៉ូលីសស្រុកហ្នឹងបានទៅសួរនាំពូហ៊ុយ?

ភាព ៖ បាទ!សួរពូហ៊ុយនោះសួរលោក ហ៊ុយ នោះ សួរថាស្រាវជ្រាវមានឈ្មោះ ដាត នៅត្រង់ណា ។ បានជាជូនមកដល់ផ្ទះខ្ញុំនេះ បានមកប៉ះយាយខ្ញុំទៅ យាយខ្ញុំថា ខ្ញុំមិនមែនឈ្មោះដាតទេ ខ្ញុំឈ្មោះ ដាក ។ ហើយប្រពន្ធខ្ញុំក៏មិនបានរស់នៅនេះដែរ រស់នៅឯស្រុកខាងជើងនោះ ។

ប្រពន្ធ ៖ ដាតនោះជាប់គុកនៅភ្នំទ្រយោងមកតាមសួរ ។

ដារ៉ា ៖ បាទ!ឈ្មោះ ដាត នេះគេប្រាប់មីង?

ប្រពន្ធ ៖ អត់ទេ!អង្គការគេប្រាប់ថា ដាត នោះជាប់គុកនៅភូមិទ្រយោង គេឲ្យសួរឈ្មោះ ដាតហ្នឹងឯងថា អ្នកទោសដែលគេវៃចោលហ្នឹងរកឈ្មោះមិនឃើញទេ ។ពូអើយ!ខ្ញុំឈ្មោះដាកអីចឹងខុសហើយ លាទៅវិញហើយ ដល់តែ តា មកពូឃុំហ្វាលគោវិញ ។

ដានី ៖ មឹងអាចមានប្រសាសន៍មួយសារទៀតថាម៉េចមិញ គេសួររកឈ្មោះ ដាត ហ្នឹង ដាត ម៉េច?

ប្រពន្ធ ៖ ដាត ថានៅជាមួយអ្នកជាប់គុកនៅភ្នំទ្រយោង រកមិនឃើញឈ្មោះហ្នឹងរកមិនឃើញទេ ។

ដារ៉ា ៖ អ្ហូ!ឈ្មោះ ដាតហ្នឹងគឺជាអ្នកដែលធ្លាប់ជាប់គុកនៅភ្នំទ្រយោង?

ប្រពន្ធ ៖ ចាំ!នៅសល់៤នាក់ណាស់អង្គការនិយាយប្រាប់ខ្ញុំថានៅសល់៤នាក់ ឈ្មោះ ដាត មួយហើយឈ្មោះអីទៀត គាត់ថានៅ៤នាក់ ភ្លេចអស់ហើយសុំទោស ។

ដារ៉ា ៖ ចុះឈ្មោះ ដាត ហ្នឹងអ្នកដែលមកសួរមឹងហ្នឹងគេមានប្រាប់ពីឪពុកម្ដាយឈ្មោះយ៉ាងម៉េច អីយ៉ាងម៉េច ហើយនៅភូមិណាអីឃុំណាទេ?

ប្រពន្ធ ៖ ថានៅព្រះនេត្រព្រះ ។

ដារ៉ា ៖ មកដល់សួរតែឈ្មោះ ដាត ?

ប្រពន្ធ ៖ បើអត់ដែលស្គាល់ភ្នំទ្រយោង នៅឆ្ងាយណាស់ ។

ដារ៉ា ៖ ហើយមកហ្នឹងមានគ្នាប៉ុន្មាននាក់ពូ?

ប្រពន្ធ ៖ មកច្រើនដែរ មានបារាំង២នាក់ហ្នឹ ។

ភាព ៖ ទេ!ដូចជាបារាំងម្នាក់ ។

ប្រពន្ធ ៖ មើស៎! ១,២,៣,៤,៥,៦នាក់ទាំងប៉ូលីស ។

ដារ៉ា ៖ ចុះពូហ៊ុយ មានបាននាំមកទេ?

ភាព ៖ អត់ទេ!អត់បានមកទេ ។

ប្រពន្ធ ៖ គាត់នាំយាយមកម្នាក់ដែរ តែយូរហើយ ។

ដារ៉ា ៖ យាយនៅកន្លែងណា?

ភាព ៖ យាយ ង៉ាន់ ។

ដារ៉ា ៖ យាយង៉ាន់ ហ្នឹងគាត់ធ្វើអីគេ?

ភាព ៖ ឈ្មោះអីគេទេ នៅជិតផ្ទះលោកហ៊ុយនោះឯង ។

ដារ៉ា ៖ អ្ហូ!គាត់នាំមក?

ភាព ៖ បាទ ។

ប្រពន្ធ ៖ ទេ!គាត់នៅភ្នំទ្រយោងនោះឯង ។

ភាព ៖ គាត់អ្នកធ្លាប់ជាប់នៅភ្នំទ្រយោង ។

ដារ៉ា ៖ អ្ហូ!ឈ្មោះយាយអី?

ភាព ៖ មិនដឹងឈ្មោះយាយអីទេ ។

ដានី ៖ ផ្ទះគាត់នៅណា?

ភាព ៖ នៅជិតផ្ទះលោកហ៊ុយនោះឯង ។

ដារ៉ា ៖ គាត់ហ្នឹងធ្លាប់ជាប់គុកនៅភ្នំទ្រយោងហ្នឹង?

ភាព ៖ បាទ!ជាប់ជិត៣ខែ ។

ដារ៉ា ៖ ជាប់៣ខែ?

ភាព ៖ បាទ!វៀតណាមចូលមក គាត់ក៏រត់មកទាំងកូន គាត់មកសម្ពាសន៍នេះដែរ ។

ដារ៉ា ៖ អីចឹងខាងតុលាការបានសម្ភាសន៍គាត់ដែរ?

ភាព ៖ បាទ!បានសម្ភាសន៍គាត់ដែរ ។

ដារ៉ា ៖ តែគេដឹងពីមុនមកឬក៏ទើបដឹងអាពេលហ្នឹង?

ភាព ៖ ទេ!មិនដឹងគេដឹងពីណាទេ អូនអើយស្រាប់តែគេថាបញ្ជូនឈ្មោះហ្នឹងទៅ ។ លោកហ៊ុយ គេប្រាប់ដឹងបានគេស្គាល់អ្នកភូមិកណ្តាល ខ្ញុំមិនសូវស្គាល់ទេអ្នកភូមិកណ្តាលហ្នឹង ។ បាទ!បានឡានគេទៅយកគាត់មកសម្ភាសន៍ៗនៅផ្ទះខ្ញុំ ចាស់ហើយ ។

ដារ៉ា ៖ យកមកសម្ភាសន៍នៅណា សម្ភាសន៍នៅផ្ទះពូនេះហ្នឹង?

ភាព ៖ បាទ!សម្ភាសន៍ខ្ញុំនេះឯង ។

ដារ៉ា ៖ អីចឹងមានបារាំងតែម្នាក់ទេ?

ភាព ៖ បាទ!មានបារាំងតែម្នាក់ទេ ក្រៅពីហ្នឹងសុទ្ធតែខ្មែរយើងទាំងអស់ ។

ដារ៉ា ៖ បារាំងចាស់ ឬក្មេង?

ភាព ៖ បាទ!ចាស់ ។

ប្រពន ៖ ទេ!បារាំង២នាក់ឬម្នាក់ឯង?

ភាព ៖ អ្ហូ!២នាក់ ក្មេងមួយ ចាស់មួយ ។

ដារ៉ា ៖ អ៊ីចឹងអ្នកដែលសួរពូហ្នឹង?

ភាព ៖ ចាស់ ។

ដារ៉ា ៖ តែបារាំងសួរ?

ភាព ៖ បាទ!បារាំងសួរ ។

ដារ៉ា ៖ មិនមែនខ្មែរយើងអ្នកសួរទេ?

ភាព ៖ ទេ!បារាំងសួររួច មានអ្នកបកប្រែឲ្យ ។

ដារ៉ា ៖ មានអ្នកបកប្រែ?

ភាព ៖ បាទ!មានអ្នកបកប្រែឲ្យ ។

ដារ៉ា ៖ ហើយសម្ភាសន៍ពូរយៈពេលប៉ុន្មានទៅពូ?

ភាព ៖ ដូចជាមិនដល់កន្លះម៉ោងទេ ប៉ុន្មាននាទីទេ ព្រោះខ្ញុំអត់មានចម្លើយឲ្យគាត់ច្រើន ។ បើយាយនោះគ្រាន់យាយហ្នឹង ។

ដារ៉ា ៖ យាយហ្នឹងគាត់សម្ភាសន៍យូរ?

ភាព ៖ បាទ!ព្រោះគាត់ធ្លាប់ជាប់គុកនៅហ្នឹងទៅ គាត់និយាយបានរឿងច្រើន បើខ្ញុំៗនិយាយមិនបានដាង១០នេះផង ហើយខ្ញុំក៏មិនដែលបានស្គាល់គាត់ច្បាស់ផង ស្គាល់តែឈ្មោះយាយចែមៗ ។

ដានី ៖ នៅភូមិណាយាយហ្នឹង?

ភាព ៖ ភូមិកណ្តាលនេះ ជិតលោកហ៊ុយ ហ្នឹងឯង ។

ដានី ៖ នៅផ្ទះពូហ៊ុយ?

ភាព ៖ បាទ! មិនស្គាល់ឈ្មោះគាត់ច្បាស់ផងខ្ញុំមិនសូវដែលបានឃើញគាត់ផង ។ ធ្លាប់តែឃើញគេដឹកយកមក យកគាត់មកឲ្យមកនៅភូមិកណ្តាល ។ គាត់និយាយគ្នាយូរ ព្រោះយាយនោះគាត់បានជួបយូរជាងខ្ញុំ បើខ្ញុំៗមិនដែលបានជួបគាត់នោះទេ ។ ថាស្គាល់ៗហ្នឹងបានជាគាត់សម្ភាសន៍ហ្នឹង ឮតែឈ្មោះហ្នឹង មិនដែលឃើញយាយចែមទេ ។

ដារ៉ា ៖ តែកាលមកហ្នឹងមិនមែនសំដៅថាមករកពូទេ?

ភាព ៖ អត់ទេ!មិនសំដៅមករកខ្ញុំទេ ។

ដារ៉ា ៖ អ៊ីចឹងពូឈ្មោះអ៊ីអ៊ីចឹង?

ភាព ៖ ខ្ញុំឈ្មោះ ភាព ។

ដារ៉ា ៖ ឈ្មោះភាព អីភាពពូ?

ភាព ៖ អ៊ុល ភាព ។ សំដៅៗមករកមនុស្សស្រីទេ សំដៅមករកមនុស្សស្រីឈ្មោះ ផាត ។ មកដល់សួររកផាត ហ្នឹងគេចន្លុលមកយាយខ្ញុំៗគាត់ឈ្មោះផាក អីចឹងសុំទោសយាយប្រទ្បាំនោះណា៎ ។ តែគាត់រៀបរកចេញទៅវិញហើយ តែខ្ញុំនេះមកពីចង់គោ គេមករកអីធ្វើអីមករកឈ្មោះយាយថែម ហើយខ្ញុំថាអ្ហូ!យាយថែម ហ្នឹងដែលតែត្រូឈ្មោះ បានគាត់ផាកមករកខ្ញុំនេះសម្ភាសន៍ខ្ញុំបណ្ដោយ ។ខ្ញុំឆ្លើយតាដំណើរដូចខ្ញុំនិយាយប្រាប់អូនហ្នឹងឯង ។ ថាត្រូតែឈ្មោះ ប៉ុនមិនដែលឃើញរូបឃើញរាងនោះទេ ប៉ុនអំណាចគាត់អ្នកណាមិនខ្លាច អ្នកស្រុកអ្នកណាមិនខ្លាចគាត់កាលសម័យ៣ឆ្នាំ ខ្លាចដូចតែគ្នាហ្នឹង ខ្ញុំនេះក៏ខ្លាច ។ ប៉ុនខ្ញុំនេះមិនដែលបានឃើញរូបព្រោះខ្ញុំប្រជាជននៅព្រះនេត្រព្រះ ។

ដារ៉ា ៖ អីចឹងយាយម្នាក់ដែលខាងតុលាការគេសម្ភាសន៍ហ្នឹង គេដឹងពី គេមករកយាយហ្នឹងហ្នុងឬក៏យ៉ាងម៉េច?

ភាព ៖ អត់ទេ!គេសួររកតែអ្នកណាធ្លាប់ជាប់គុកនៅភ្នំទ្រយោង រកអាឈ្មោះ ផាត ហ្នឹងមិនឃើញហើយណាស ។ គេសួរថាអ្នកណាធ្លាប់ជាប់គុកនៅភ្នំទ្រយោង បានមេឃុំគេប្រាប់ភ្លាមថាយាយ នោះធ្លាប់ជាប់គុក ។

ដារ៉ា ៖ អីចឹងកាលមកដំបូងគឺសំដៅរកតែឈ្មោះផាតហ្នឹងទេ?

ភាព ៖ បាទ!សំដៅរកតែផាតទេ ។

ដារ៉ា ៖ ហើយដោយសារថារកផាត មិនឃើញហ្នឹងក៏សួរជាមួយប្រធានឃុំអីហ្នឹង?

ភាព ៖ បាទ!

ដារ៉ា ៖ ថាអ្នកណាធ្លាប់ជាប់គុកនៅភ្នំទ្រយោងអីចឹង?

ភាព ៖ បាទ!ភ្នំទ្រយោង ។

ដារ៉ា ៖ អីចឹងគេតាមហ្នឹងទៀតទៅ?

ភាព ៖ បាទ ។

ដានី ៖ តាមយកសម្ភាសហ្នឹងវិញ?

ភាព ៖ បាទ!យកមកនេះឯង ។

ប្រពន្ធ ៖ “មិនបាត់ភ័យទេណាអ៊ឹ! ខ្ញុំថាខ្ញុំអត់មានភ័យទេ” ខ្ញុំមិន មែនឈ្មោះចឹងគាត់សើច ។

ដារ៉ា ៖ ហើយគេបានប្រាប់ច្បាស់លាស់ទេថា មកពីខាងណា?

ភាព ៖ បាទ! មកពីភ្នំពេញខ្ញុំសួរថាមកពីភ្នំពេញ ។

ដារ៉ា ៖ នៅភ្នំពេញ តែគេបានប្រាប់ច្បាស់ទេថាជាស្អី មានមុខជំណែងអីទេ?

ភាព ៖ ទេ!ខ្ញុំមិនហ៊ានសួរគេទេ មិនហ៊ានសួរផង ប៉ុន្តែគេប្រាប់ថាជាតុលាការថៅក្រមកាត់ទោស ខ្មែរក្រហម ស្រាវជ្រាវប្រវត្តិរូបយាយចែម ។

ដារ៉ា ៖ ហើយពេលសម្ភាសន៍ពូហ្នឹងគេបានវ៉ៃ?

ភាព ៖ បាទ!វ៉ៃអានេះ វ៉ៃអន្ទុលីលេខ ។

ដារ៉ា ៖ ដូចអន្ទុលីលេខហ្នឹង?

ភាព ៖ បាទៗ ។

ដារ៉ា ៖ វ៉ៃតាមចម្លើយរបស់ពូ?

ភាព ៖ បាទ!តាមចម្លើយរបស់ខ្ញុំ ។

ដារ៉ា ៖ ហើយសួរប៉ុន្មានសំនួរពូ?

ភាព ៖ សួរខ្ញុំមួយ សួរថាខ្ញុំរស់នៅនេះពិតប្រាកដ ខ្ញុំថាខ្ញុំរស់នៅនេះពិតប្រាកដ ភូមិព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។ ហើយកាលសម័យពន្ធាំនោះពូឯងធ្វើអីខ្លះ? ខ្ញុំថាខ្ញុំកាលសម័យ ពន្ធាំខ្ញុំជួយធ្វើប្រជាជនធ្វើស្រែ ឃ្វាលគោ ។ ហើយចុះបើពូឯងម៉េចក៏បាន ទំនាក់ទំនង បានស្គាល់ យាយ ចែម? ខ្ញុំថាយាយចែម ខ្ញុំស្គាល់ដោយសារតែខ្ញុំដឹកអង្ករយកទៅឲ្យគេ អ្នកចល័ត ពុតែឈ្មោះមិនដែលបានឃើញរូបទេ គាត់ធ្វើប្រធានធំប្រាប់ខ្ញុំថានេះគឺ យាយ ចែម គណៈស្រុកយើង ។ ខ្ញុំក៏មកវិញល្ងាចទៅ ហើយបានគាត់សួរចម្លើយមកទៀតថា ចុះសព្វ ថ្ងៃពូឯងខ្វាចទេ? ខ្ញុំឈប់ខ្វាចហើយសព្វថ្ងៃ មានឪម៉ែគ្រប់គ្រងហើយនៅខ្វាចអី ប៉ុណ្ណោះឯងចម្លើយខ្ញុំគ្មានអី ។

ដារ៉ា ៖ អ៊ីចឹង ហើយដល់ពេលហើយទៅ គេបានយកក្រដាសអីទៅផ្តិតមេដៃអីដែរ?

ភាព ៖ បាទ!គេផ្តិតមេដៃឲ្យខ្ញុំមើលពី គេបញ្ជាក់ហើយបញ្ជាក់ទៀតនឹងចម្លើយខ្ញុំឆ្លើយនោះ ។

ដារ៉ា ៖ គេបានអានចម្លើយហ្នឹង ជៀនឲ្យពូ?

ភាព ៖ បាទ!អានចម្លើយជៀនឲ្យខ្ញុំស្តាប់ទៅដូចដែលខ្ញុំនិយាយចឹងឯង ។

ដារ៉ា ៖ អីចឹងពូក៏សុខចិត្តផ្តិតមេដៃហ្នឹងទៅ?

ភាព ៖ បាទ!ផ្តិតមេដៃឲ្យ ។

ដារ៉ា ៖ ហើយគេមានបានទុកក្រដាសស្នាមអី?

ភាព ៖ ទុកដែរប៉ុនវាបាត់ទៅហើយ ខ្ញុំគ្មានបានដាយកចិត្តទុកដាក់ទេ ចៅខ្ញុំវាច្រើន ។

ដារ៉ា ៖ ទេ!ចង់និយាយថាបានឬមិនបានទុក?

ភាព ៖ បានទុក ។

ដារ៉ា ៖ គេcopy ទុកឲ្យយើងមួយច្បាប់ដែរ?

ភាព ៖ បាទ!បានមួយច្បាប់ដែរ ប៉ុនមិនដឹងទៅណាមកណីទេ មិនបានទុកដាក់ព្រោះកូនចៅវាច្រើន រើរុសទៅមិនទុកខាងណាមកខាងណីទេ មិនសូវយកចិត្តទុកដាក់ទេ ប៉ុនគេcopy ឲ្យដែរ ។

ដារ៉ា ៖ សំខាន់រឿងថាខាងតុលាការគេទុកសំណៅមួយសំណៅដែរ?

ភាព ៖ បាទ!ទុកមួយសន្លឹក ។ ខ្ញុំមិនបានមើលទេ មិនបានយកចិត្តទុកដាក់ កូនចៅខ្ញុំក៏មិនបានមើល ។

ដារ៉ា ៖ ចុះពេលដែលតុលាការចុះមកពូ តុលាការគេមានបង្ហាញលិខិតស្នាមអីឲ្យពូមើលទេ?

ភាព ៖ ទេ!អត់ទេ អត់មានឲ្យមើលទេ ។ លិខិតស្នាមម៉េច?

ដារ៉ា ៖ ចង់និយាយថា មកដល់គេបានបង្ហាញពី បញ្ជាក់ថាគេធ្វើជាតុលាការធ្វើចៅក្រមអី ឈ្មោះអីៗ គេបាន...?

ភាព ៖ អត់ទេ!អត់បានប្រាប់ទេ ។

ដារ៉ា ៖ អត់មានទេ?

ភាព ៖ បាទ!

ដារ៉ា ៖ មកដល់ តែគ្រាន់តែថាមកជាមួយឡានប៉ូលីស មានឡានប៉ូលីស?

ភាព ៖ ឡានអញ្ចេះឯង បើប៉ូលីសម្នាក់ជូនមក ជូនមករកឈ្មោះ ។

ប្រពន្ធ ៖ ប៉ូលីសជិះម៉ូតូ អ្នកភូមិគេអ្នកឲ្យដើររកឈ្មោះមេភូមិប្រាប់ឲ្យមក ។

ដារ៉ា ៖ បាទ!អីចឹងដល់ពេលត្រឡប់ទៅវិញទៅ ខាងតុលាការគេគ្រាន់តែបានទុកក្រដាសស្នាមហ្នឹងទេ ហើយគេបាននិយាយថាយ៉ាងម៉េចខ្លះទៀតពូ ទាក់ទងនឹងការមិនឲ្យភ័យមិនឲ្យអីនោះ?

ភាព ៖ អត់ទេ! អត់មាននិយាយអីច្រើនទេ គេថាអឹងឯងមិនបាច់ភ័យទេ នេះស្រាវជ្រាវចង់ដឹងប្រវត្តិយាយថែម ថាតើអ្នកណាស្គាល់គាត់ច្បាស់ពិតប្រាកដ អ្នកណាធ្លាប់បានជាប់គុកនោះគេរកតែអ្នកជាប់គុកទេ ព្រោះអ្នកដែលនៅជាប់គុកភ្នំទ្រយោងគេថានៅរស់នៅក្នុងភូមិនេះ ៨,៩នាក់ តែឈ្មោះ ដាត នេះច្បាស់ គេរកឈ្មោះនេះឯងតែរកមិនឃើញ ។ រកមិនឃើញប្រុស្ស ឈ្មោះប្រពន្ធខ្ញុំឈ្មោះ ដាក បានជាមិនជួបទេ លាទៅវិញហើយ ហើយខ្ញុំមកពីឃ្វាលគោវិញ ខ្ញុំឆ្លើយតែមួយមាត់ហ្នឹងក៏រងជាប់ខ្ញុំសើច..ប្រពន្ធនិយាយបន្តថាខ្ញុំមិនដែលស្គាល់ យាយ ថែម ទេខ្ញុំនៅស្រុកឆ្ងាយ ភូមិឆ្ងាយ ។

ដានី ៖ បាទ!អីចឹងខ្ញុំចង់សួរនាំពូបន្តិចទាក់ទង់នឹងប្រវត្តិរបស់ពូ ថាពូធ្លាប់រស់នៅតាំងពីក្មេង រហូតដល់សម័យប៉ុល ពត ។ អីចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូពេញ ពូឈ្មោះអី?

ភាព ៖ ឈ្មោះ អ៊ិល ភាព ។

ដានី ៖ អ៊ិល ភាព! ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ភាព ៖ សព្វថ្ងៃ៦២ហើយ ។

ដានី ៖ ស្រុកកំណើតកើតជានៅណាពូ?

ភាព ៖ បាទ!នៅនេះឯង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះនេះ ។

ដានី ៖ ស្រុកកំណើតនៅភូមិអីគេ?

ភាព ៖ ភូមិប៉ុស្តិ៍ចាស់ ។

ដានី ៖ ឃុំព្រះនេត្រព្រះហ្នឹង?

ភាព ៖ បាទ!ស្រុកព្រះនេត្រព្រះ ។

ដានី ៖ បាទ!ចុះសព្វថ្ងៃ រស់នៅក្នុងភូមិ ឃុំ ស្រុកអីដែរ?

ភាព ៖ នៅប៉ុស្តិ៍ចាស់ ព្រះនេត្រព្រះនេះឯង ។

ដានី ៖ នៅប៉ុស្តិ៍ដដែល?

ភាព ៖ បាទ ។

ដានី ៖ ហើយគ្រួសារពូឈ្មោះអីដែរ?

ភាព ៖ គុយ ដាក ។

ដានី ៖ គុយ ដាក ។ គាត់អាយុប៉ុន្មានដែរ?

ដាក ៖ ហា ហុកហើយកូន៦០ហើយ ។

ភាព ៖ ៦០គត់ ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ភាព ៖ កូនខ្ញុំ៨នាក់ រស់នៅ៧ អុំះ!៦នាក់ ។

ប្រពន្ធ ៖ ១០នាក់ ។

ដានី ៖ បាទ!អីចឹងឥឡូវនៅសល់១០នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ស្រី៦នាក់ ប្រុស៤នាក់ ។

ដានី ៖ ហើយពូឪពុកម្ដាយពូឈ្មោះអីដែរ?

ភាព ៖ ឪពុកខ្ញុំឈ្មោះគោក នង គោក១ ។

ដានី ៖ គោក នង គាត់ស្លាប់ហើយ?

ភាព ៖ បាទ!ស្លាប់ហើយ ។

ដានី ៖ ស្លាប់តាំងពីអន្កាល់?

ភាព ៖ ស្លាប់៤,៥,៦ឆ្នាំហើយ ។

ដានី ៖ ចុះម្ដាយ?

ភាព ៖ ម្ដាយគាត់ខូចហើយ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

ភាព ៖ ធេត អ៊ិន់ ។

ដានី ៖ ធេត អ៊ិន់ គាត់ស្លាប់ដែរហើយ?

ភាព ៖ បាទ!ស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់ពីអន្កាល់?

ភាព ៖ ពីសម័យសាធារណៈរដ្ឋ ។

ដានី ៖ បាទ!បងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ភាព ៖ ខ្ញុំ៣នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ស្រី១នាក់ ប្រុស២នាក់ ស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់អស់ហើយ?

ភាព ៖ បាទ!

ដានី ៖ ពូកូនទីប៉ុន្មាន?

ភាព ៖ ខ្ញុំកូនទី២ ។

ដានី ៖ ចុះកាលពីក្មេងៗបានរៀនសូត្រអីដល់ណា?

ភាព ៖ បាទ!ខ្ញុំរៀនបានថ្នាក់ទី៧ កាលពីសង្គមសម័យពីដើម ។

ដានី ៖ នៅសាលាណា?

ភាព ៖ នៅសាលាព្រះនេត្រព្រះនេះឯង ។

ដានី ៖ ថ្នាក់ទី៧ នៅសាលាព្រះនេត្រព្រះ ។ ចុះពេលឈប់រៀនហើយនៅធ្វើអីទៀតទៅ?

ភាព ៖ ឈប់រៀនរួចខ្ញុំធ្វើតែស្រែ ។

ដានី ៖ ធ្វើស្រែនៅភូមិកំណើតហ្នឹង?

ភាព ៖ បាទ!នៅភូមិកំណើតនេះឯង ។

ដានី ៖ ធ្វើស្រែបានរយៈពេលប៉ុន្មានទៅ?

ភាព ៖ បើពីសម័យសាធារណៈខ្ញុំធ្វើបានច្រើន រាប់ពាន់ចាំងដែរហ្នឹង ។

ដានី ៖ បាទ!ប៉ុនធ្វើបានប៉ុន្មានឆ្នាំទៅបានស្រុកកើតសង្គ្រាមកើតអី?

ភាព ៖ បាទ!ខ្ញុំធ្វើបាន តាំងពីអាយុ១៥មកដល់អាយុ២១ ស្រុកកើតសង្គ្រាមបណ្តោយ ។

ដានី ៖ ស្រុកកើតសង្គ្រាម អាយុ១៥ដល់២១?

ភាព ៖ បាទ!

ដានី ៖ កាលហ្នឹងពូមានគ្រួសារហើយនៅ?

ភាព ៖ ដល់អាយុខ្ញុំ២១មានគ្រួសារហើយ ។

ដានី ៖ ចឹងអាយុ២១ហ្នឹងមានគ្រួសារ?

ភាព ៖ បាទ ។

ដានី ៖ ឆ្នាំណា?

ភាព ៖ ឆ្នាំ៧៥ ។

ដានី ៖ ចឹងពូរៀបការឆ្នាំ៧៥តែម្តង?

ភាព ៖ បាទ!ហ្អេ! ខ្ញុំរៀប៧៤ រួចដល់៧៥សង្គ្រាម ។

ដានី ៖ ឆ្នាំ៧៥ចុះដល់ឆ្នាំ៧៥ ។ ចុះដល់ពេលគ្រួសារលោកពូជាអ្នកស្រុកកំណើតនៅហ្នឹងដែរឬគាត់ជាអ្នកនៅឯណា?

ភាព ៖ ទេ!គ្រួសារខ្ញុំវាពីរ គ្រួសារដែលរៀបកាលអាយុ២១មកស្លាប់សម័យបីឆ្នាំ ហើយយាយក្រោយបានសម័យយួនចូលវៀតណាម ។ វៀតណាមចូលឆ្នាំ៨០គត់ ហួស!៧៩ ។

ដានី ៖ ចឹងគ្រួសារលោកពូមុនឈ្មោះអីទៅ?

ភាព ៖ ឈ្មោះ បូរី ។

ដានី ៖ គ្រួសារមុនឈ្មោះ បូរី?

ភាព ៖ បាទ!

ដានី ៖ ចឹងគាត់ស្លាប់ឆ្នាំណា?

ភាព ៖ ស្លាប់ឆ្នាំ៧៧ ។

ដានី ៖ ស្លាប់ឆ្នាំ៧៧?

ភាព ៖ បាទ ។

ដានី ៖ កាលហ្នឹងពូមានកូនចៅប៉ុន្មាននាក់ដែរ?

ភាព ៖ មានកូនពីរ ។

ដានី ៖ កូនពីរ?

ភាព ៖ បាទ!ប្រុស១ស្រី១ ។

ដានី ៖ ប្រុស១ស្រី១គាត់នៅរស់ទាល់តែឥឡូវហ្នឹង?

ភាព ៖ បាទ!រស់នៅសព្វថ្ងៃ ។

ដានី ៖ បាទ!ចុះដល់ពេលបែកឆ្នាំ៧៥មក កាលហ្នឹងពូរស់នៅឯណាគេឲ្យទៅនៅណាធ្វើអីទៅ?

ភាព ៖ ខ្ញុំគេចល័តពីនេះនៅខាងនោះភ្នំនេះ ជើងភ្នំនេះធ្វើស្រែដែរ ។

ដានី ៖ ធ្វើស្រែ?

ភាព ៖ បាទ! ធ្វើស្រែសាបស្ទូង ។

ដានី ៖ សាបស្ទូង?

ភាព ៖ បាទ ។

ដានី ៖ ចុះប្រពន្ធ?

ភាព ៖ ប្រពន្ធគាត់ទៅខាងចម្ការ ធ្វើចម្ការដាំដំឡូង ។

ដានី ៖ ធ្វើចម្ការ?

ភាព ៖ បាទ ។

ដានី ៖ យើងនៅជាមួយគ្នាឬមួយបែកគ្នា?

ភាព ៖ នៅជុំគ្នា ។

ដានី ៖ ចឹងពួគេជម្លៀសឲ្យទៅនៅក្បែរភ្នំ?

ភាព ៖ បាទ! ក្បែរភ្នំ ។

ដានី ៖ ភ្នំអីគេ?

ភាព ៖ ភ្នំព្រះនេត្រព្រះហ្នឹងឯង ។

ដានី ៖ ចឹងធ្វើស្រែ?

ភាព ៖ បាទ! ធ្វើស្រែ ។

ដានី ៖ ធ្វើអីទៀតក្រៅពីធ្វើស្រែ?

ភាព ៖ គ្មានធ្វើអីទេ ខ្ញុំធ្វើស្រែរហូតគេឲ្យខ្ញុំនៅតែស្រែ សាប ស្ទូង នឹងគោហ្នឹងឯងឡើងចប់មកវិញទេហ្នឹង ។

ដានី ៖ កាលហ្នឹងប្រធានភូមិឈ្មោះអី?

ភាព ៖ ឈ្មោះ ឆែម ។

ដានី ៖ ឈ្មោះ ខែម?

ភាព ៖ ឈ្មោះ ឆែម មកពីស្រុកឯកើតនោះមិនដឹងជាមកពីណា មកកាន់កាប់ស្រុកនេះ ។

ដានី ៖ ស្រុកកើតស្រុកខាងណា?

ភាព ៖ ស្រុកអីកើតមិនដឹងជាស្រុកខាងណា ខ្ញុំដឹងថាមកពីខាងបេងបត់ៗមិនដឹងនៅឯណាវិញ ។

ដានី ៖ បេងបត់ហ្នឹងនៅខាងស្រុកព្រះនេត្រព្រះ?

ភាព ៖ ទេ! ខាងខេត្តសៀមរាបនោះ ។

ដានី ៖ នៅខាងខេត្តសៀមរាប?

ភាព ៖ បាទ!សៀមរាបមិនដឹងជានៅត្រង់ណាមិនដែលបានទៅ មិនដែលឃើញ ។

ដានី ៖ ឈ្មោះ ឆែម?

ភាព ៖ បាទ!ឈ្មោះ ឆែម ។

ដានី ៖ ចឹងគណៈឃុំ?

ភាព ៖ គណៈឃុំឈ្មោះ ក្រុក ។

ដានី ៖ ឈ្មោះ ក្រុក?

ភាព ៖ បាទ!ងាប់អស់ ។

ដានី ៖ ក្រុកហ្នឹងមកពីខាងណាមក?

ភាព ៖ មកពីខាងកើតនោះមកដែរ ។

ដានី ៖ មកពីកើតដែរ?

ភាព ៖ បាទ ។

ដានី ៖ កើតហ្នឹងសំដៅអ្នកមកសៀមរាបមកប្រមូលយ៉ាងម៉េច?

ភាព ៖ បាទ!ទឹកដីសៀមរាប ។

ដានី ៖ គណៈឃុំឈ្មោះ ក្រុក គណៈឃុំព្រះនេត្រព្រះហ្នឹង?

ភាព ៖ បាទ ។

ដានី ៖ ចុះគណៈស្រុក?

ភាព ៖ គណៈស្រុក យាយ ចែម ហ្នឹងឯង ។

ដានី ៖ ចុះមុនយាយចែម?

ភាព ៖ មុន យាយ ចែម ខ្ញុំអត់ស្គាល់ទេ មិនដែលស្គាល់ទេ ។

ដានី ៖ មិនដែលស្គាល់ទេ?

ភាព ៖ បាទ!មិនដែលស្គាល់ទេ ។

ដានី ៖ ចឹងកាលហ្នឹងលោកពូធ្វើស្រែនៅហ្នឹងរហូត?

ភាព ៖ បាទ!ធ្វើតែស្រែរហូត ។

ដានី ៖ អត់មានទៅណា?

ភាព ៖ អត់មានទៅណាទេ ខ្ញុំគេឲ្យកាន់តែន័ង្គលភ្ជួរសាបដកស្ទូងរហូត ។

ដានី ៖ ចឹងលោកពូពុកឈ្មោះយាយបែមតាំងពីអន្លាល?

ភាព ៖ យាយបែមពុកឆ្នាំ៧៦ហ្នឹង ។

ដានី ៖ ពុកឆ្នាំ៧៦?

ភាព ៖ បាទ?

ដានី ៖ ពុកថាយ៉ាងម៉េច?

ភាព ៖ ពុកថា យាយ បែម មកនៅទឹកដីខេត្តព្រះនេត្រព្រះហ្នឹងហើយធ្វើជាគណៈស្រុក ។

ដានី ៖ ធ្វើជាគណៈស្រុក?

ភាព ៖ បាទ ។

ដានី ៖ កាលហ្នឹងផ្ទះគាត់នៅឯណា យាយ បែម?

ភាព ៖ ទេ!មិនដឹងជាស្រុកខាងណាខាងណីទេគាត់មកនៅពុកថានៅភ្នំលៀបៗអត់ដឹងស្រុកស្រែគាត់នៅខាងណាទេ ។

ដានី ៖ បាទ!តែគាត់មកនៅមកធ្វើជាគណៈស្រុកហ្នឹងគាត់នៅភ្នំលៀប?

ភាព ៖ បាទ ។

ដានី ៖ ផ្ទះគាត់នៅភ្នំលៀប?

ភាព ៖ បាទៗ!នៅភ្នំលៀបហ្នឹងហើយ ។

ដានី ៖ អត់ដឹងថាគាត់ផ្លាស់មកពីខាងណាទេ?

ភាព ៖ បាទ!អត់ដឹងមិនថាផ្លាស់មកពីខាងណាខ្ញុំអត់ដឹង ។

ដានី ៖ អត់ដឹងថាគាត់មកពីណា?

ភាព ៖ បាទ!អត់ដឹងទេ ។

ដានី ៖ ចឹងពូថា ពូធ្លាប់ទៅ?

ភាព ៖ ធ្លាប់ទៅដឹកអង្ករអីឲ្យអ្នកចល័ត ។

ដានី ៖ ដឹកអង្ករពីខាងណាទៅ?

ភាព ៖ ពីភូមិខ្ញុំនេះឯងពីស្រុកពីភូមិខ្ញុំនេះទៅ ។

ដានី ៖ ម៉េចបានជាគេឲ្យពូដឹកពីហ្នឹងទៅ?

ភាព ៖ គេប្រាប់គេប្រើដឹកយកទៅឲ្យចល័តហូប ។

ដានី ៖ ប្រធានភូមិប្រើឲ្យដឹកឲ្យចល័តហូប?

ភាព ៖ បាទ! តា ឆែម ។

ដានី ៖ ឆ្នាំណាហ្នឹង?

ភាព ៖ ឆ្នាំណាទេ ភ្លេចទៅហើយដឹងជាឆ្នាំណាដឹកទៅហ្នឹង ។

ដានី ៖ ចឹងកាលហ្នឹងប្រពន្ធនៅរស់ឬមួយស្លាប់ហើយ?

ភាព ៖ ស្លាប់ហើយ ។

ដានី ៖ ប្រពន្ធពូស្លាប់ឆ្នាំ៧៧?

ភាព ៖ បាទ ។

ដានី ៖ ស្លាប់បានរយៈពេលប៉ុន្មានបានគេឲ្យពូដឹកអង្ករទៅ?

ភាព ៖ ស្លាប់មើលកូនខ្ញុំបានបីខែបួនខែប៉ុណ្ណោះឯងឲ្យដឹកទៅ គេឲ្យខ្ញុំឈប់នៅភ្នួរគេឲ្យខ្ញុំទៅនៅភូមិជួយ... ។

ដានី ៖ កូនបានបីបួនខែ កាលហ្នឹងកូនពូកើតឆ្នាំណា?

ភាព ៖ ឆ្នាំណាទេ កូនអើយភ្លេចហើយឆ្នាំ៧៦ឆ្នាំ៧៧ កំណើតកូនកើតឆ្នាំនោះប្រពន្ធស្លាប់ឆ្នាំនោះឯង ។

ដានី ៖ តែកូនឆ្នាំអីឆ្នាំខ្មែរយើង?

ភាព ៖ ឆ្នាំម្សាញ់ ។

ដានី ៖ ឆ្នាំម្សាញ់?

ភាព ៖ បាទ ។

ដានី ៖ កូនឆ្នាំម្សាញ់ហ្នឹងបានតែពីរបីខែទេគេឲ្យដឹក?

ភាព ៖ ដឹកទៅដឹកតែមួយជើងគត់ប៉ុណ្ណោះឯង ។

ដានី ៖ ប៉ុន្តែគាត់ឈឺអីបានគាត់ស្លាប់?

ភាព ៖ គាត់ទាស់សរសៃរខ្ចីអត់មានអីហូប ហូបស៊ីកឈើទៅទាស់សរសៃរខ្ចី ។

ដានី ៖ ចឹងពេលកូនខ្ចីបានបីខែហ្នឹងប្រធានភូមិឈ្មោះអែមហ្នឹងឲ្យទៅដឹកអង្ករទៅចល័ត?

ភាព ៖ បាទ!ដឹកយកទៅឲ្យចល័ត ។

ដានី ៖ ដឹកយកឲ្យចល័តនៅណា?

ភាព ៖ នៅភ្នំលៀបហ្នឹងឯង ។

ដានី ៖ ដឹកអង្ករទៅភ្នំលៀប?

ភាព ៖ បាទ ។

ដានី ៖ ចុះពូទៅដល់ភ្នំលៀបហ្នឹងពូមានដឹងដំណឹងថាម៉េច?

ភាព ៖ ពុថា យាយ ចែម ហ្នឹងឯងជាគណៈស្រុកយើងជាប្រធានស្រុកអីចេះ ។

ដានី ៖ ចឹងកាលពីមុនដឹកអង្ករទៅពូមិនដែលពុឈ្មោះ យាយ ចែម ទេ?

ភាព ៖ បាទ!មិនដែលឮទេ យាយ ចែមៗនៅស្រុកយើងមិនដែលពុទេ ។

ដានី ៖ មិនដែលពុទេ?

ភាព ៖ បាទ!មិនដែលពុទេ ពួកចល័តទៅភ្នំស្រុក ខ្ញុំទៅពីនេះទាំងអស់គ្នាទៅនៅដឹកប្រឡាយអីនោះ ភ្នំលៀបនោះឯង ដល់ទៅគេថាគណៈស្រុកយើងហ្នឹងឈ្មោះ យាយ ចែម តែខ្ញុំមិនដែលបានឃើញរូបរាងទេ ។

ដានី ៖ ពូមិនដែលបានឃើញគាត់ទេ?

ភាព ៖ បាទ ។

ដានី ៖ បាទ!កាលពូដឹកអង្ករទៅដាក់ភ្នំលៀបហ្នឹងដឹកទៅដាក់ម្តុំណា?

ភាព ៖ អីកើតភ្នំលៀបហ្នឹងជិត តា ប៉ុន ។

ដានី ៖ ជិតតាប៉ុន?

ភាព ៖ គេហៅអូរលៀសៗ ។

ដានី ៖ អូរអីគេ?

ភាព :	អូរលើស ។

ដានី :	អូរលើស?

ភាព :	បាទ!កង់ចល័តជីកតែនោះឯង ធ្វើនោះឯង នៅនោះឯង ។

ដានី :	ជីកអី?

ភាព :	ជីកប្រឡាយ ហ្នឹងឯង ជីកអូរ ហ្នឹង ដីស្មើ យើងធ្វើជាអូរ ប្រឡាយ ធ្វើស្រែប្រាំង ។

ដានី :	ជីកអន្លុរទៅស្នាក់នៅហ្នឹងប៉ុន្មានថ្ងៃទៅ?

ភាព :	ទេ!មិនបានសម្រាកទេ ទៅទម្លាក់ឲ្យទៅគេខ្ញុំហូបបាយរួចមកវិញ ។

ដានី :	ជីកទៅតែម្ដងហ្នឹងទេ?

ភាព :	បាទ!ជីកតែម្ដងក៏ប៉ុណ្ណោះឯង ខ្ញុំឈប់ទៅទៀត គេឈប់ប្រើទៀត ។

ដានី :	ចឹងឬឈ្មោះ យាយ ចែម តែម្ដងហ្នឹងទេ?

ភាព :	បាទ!ពូតែម្ដងហ្នឹងឯង ។

ដានី :	ចឹងមកដល់ភូមិវិញអត់មានពូទេ?

ភាព :	ទេ!មិនដែលបាននិយាយពូទេ ព្រោះគាត់មិនដែលមកនេះទេ នៅតែភ្នំលៀប ។

ដានី :	នៅតែភ្នំលៀប?

ភាព :	បាទ ។

ដានី :	ចឹងពូត្រឡប់មកវិញគេឲ្យពូធ្វើអីទៀតទៅ?

ភាព :	ចូលព្រោះស្រូវ ធ្វើស្រែសាបស្ទូងទៀតទៅ នៅជិតៗ ហ្នឹងទៅគេឲ្យមើលកូនខ្ចីផងគេឲ្យសាប
	នៅជិតៗ នេះឲ្យម៉ែៗ យើងដកទៅឆ្ងាយមិនរួច ។

ដានី :	បាទ ។

ភាព :	សាបស្ទូងទៅម៉ែៗគាត់ដកទៅភ្ជួរដីឲ្យគាត់ស្ទូងផង ។

ដារ៉ា :	ចឹងអន្លុរដែលពូជីកទៅហ្នឹងសម្រាប់យកទៅផ្គត់ផ្គង់កង់ចល័តហ្នឹង?

ភាព :	បាទ!យកទៅឲ្យកង់ចល័តយកទៅឲ្យអ្នកចល័តហូប ។

ដារ៉ា :	ជីកទៅម្ដងៗមានអន្លុរប៉ុន្មានបាវ?

ភាព :	បីបាវ ។

ដារ៉ា ៖ បីបាវ?

ភាព ៖ បាទ ។

ដារ៉ា ៖ បីបាវមានតែប៉ុន្មានគីឡូហ្នឹង១៥០គីឡូហ្នឹង?

ភាព ៖ បាទ!ទេបីបាវហ្នឹងចង់បីរយគីឡូ ។

ដានី ៖ ចង់បីរយគីឡូ?

ភាព ៖ បាទ!បាវពោះឈ្នើងយើងអាធំ ។

ដារ៉ា ៖ ហើយមួយកងចល័តមានគ្នាប្រហែលជាប៉ុន្មាននាក់កាលហ្នឹង?

ភាព ៖ ទេ!មិនដឹងទេមិនជាមានប៉ុន្មានៗអឺមិនបានសួរនាំថាប៉ុន្មាននាក់អីទេ ទុកឲ្យគេរួចចុងភៅគេទទួលក៏ត្រឡប់មកវិញទៅ ។

ដារ៉ា ៖ ចុះខាងណាប្រាប់ឲ្យពូដឹកអង្ករទៅ?

ភាព ៖ ប្រធានភូមិ ។

ដារ៉ា ៖ ប្រធានភូមិ?

ភាព ៖ ប្រធានភូមិឈ្មោះ ឆែមដែលងាប់ហ្នឹង ។

ដារ៉ា ៖ តា ឆែម ឲ្យដឹកទៅ?

ភាព ៖ បាទ!ឲ្យដឹកទៅឲ្យគេ ។

ដារ៉ា ៖ ចឹងពេលដឹកទៅដល់កន្លែងភ្នំល្មៀបហ្នឹងមានគេទទួលអីត្រឹមត្រូវទេ?

ភាព ៖ បាទ!មានចុងភៅគេជាអ្នកទទួលត្រឹមត្រូវ ។

ដារ៉ា ៖ ដឹកទៅដាក់កន្លែងចុងភៅហ្នឹង?

ភាព ៖ បាទ!ដឹកទៅកន្លែងចុងភៅគេតែម្ដង ។

ដារ៉ា ៖ ចុងភៅគេឈ្មោះអីដែលទទួលពូ?

ភាព ៖ ហួស !ខ្ញុំភ្លេចឈ្មោះហើយប្រជាជនថ្មីអ្នកខាងភ្នំពេញហ្នឹងឯង ។

ដារ៉ា ៖ ចឹង?

ភាព ៖ បាទ!អ្នកភ្នំពេញហ្នឹងឯងដែលចល័តនោះ ។

ដារ៉ា ៖ ម៉េចអ្នកភ្នំពេញអាចធ្វើជា?

ភាព ៖ អ្នកអរិយក្សត្រនោះអារិយអីទេអ្នកភ្នំពេញមានបានធ្វើចុងភៅអីដែលតើអូន ព្រោះអ្នកណាដែលមេម៉ាយកំលាំងពលាំងធំទៅធ្វើការរហ័សគេឲ្យធ្វើចុងភៅដែលតើ ។

ដារ៉ា ៖ ចឹង?

ភាព ៖ បាទ!មិនមែនចាំតែប្រជាជនចាស់ទេ ប្រជាជនថ្មីដែលចល័តមកក៏គេឲ្យធ្វើចុងភៅបាន ដែរតែមនុស្សនោះត្រង់ហើយកំលាំងពលាំងអាចធ្វើឲ្យគេបាន គេឲ្យធ្វើទៅ ។

ដារ៉ា ៖ អីចឹងក្នុងអំឡុងពេលរបបខ្មែរក្រហមហ្នឹងពូធ្លាប់ដឹកអង្ករទៅប៉ុន្មានដងពូ?

ភាព ៖ ទៅមួយដើងប៉ុណ្ណោះឯងខ្ញុំ ។

ដារ៉ា ៖ មួយដើងគត់?

ភាព ៖ បាទ!មួយដើងដែលប្រពន្ធខ្ញុំស្លាប់កូនងាំកូនខ្ទីគេឲ្យដឹកតែមួយដើងមកវិញនៅមើលកូនជុំវិញមើលកូនភ្លូរស្រែជិតៗនេះ ។

ដារ៉ា ៖ ក្នុងឆ្នាំណាដែលពូដឹកទៅ?

ភាព ៖ ឆ្នាំ៧៧ ។

ដារ៉ា ៖ ឆ្នាំ៧៧?

ភាព ៖ បាទ ។

ដារ៉ា ៖ ចឹងក្នុងឆ្នាំ៧៧ពេលដែលពូដឹកអង្ករយកទៅកន្លែងភ្នំលាបហ្នឹង គឺពូបានព្រុឈ្មោះ យាយចែម?

ភាព ៖ ឈ្មោះ យាយ ចែម បានព្រុឈ្មោះគេថា យាយ ចែម គណៈស្រុក ។

ដារ៉ា ៖ ហើយ៧៧ហ្នឹងវាដើមឆ្នាំឬមួយចុងឆ្នាំ?

ភាព ៖ ចុងឆ្នាំហើយប្រពន្ធខ្ញុំស្លាប់ចុងឆ្នាំហើយជិតចប់ហើយនោះ ។

ដារ៉ា ៖ ជិតចប់៧៧ហ្នឹង?

ភាព ៖ បាទ!យើងដែលចប់នេះ៧៧ ដែលចប់វៀតណាមរំដោះបាន ។

ដារ៉ា ៖ ៧៩ ។

ភាព ៖ ៧៩ ចឹង៧៧ដែលខ្ញុំទៅ ។

ដារ៉ា ៖ ចឹងពូទៅដឹកអង្ករទៅ៧៧?

ភាព ៖ បាទ ។

ដារ៉ា ៖ ចុង៧៧?

ភាព ៖ បាទ!ចុង៧៧ចូល៧៨ហ្នឹង ។

ដារ៉ា ៖ ចឹង៧៧ចូល៧៨ហ្នឹងពូដឹកអង្ករទៅហើយបានឮឈ្មោះ យាយ ថែម?

ភាព ៖ បាទ!គេប្រាប់ថា យាយ ថែម ជាគណៈស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ តែគ្រាន់តែថាពូមិនដែលបានឃើញ?

ភាព ៖ បាទ!មិនដែលបានឃើញរូបទេ មិនដែលឃើញមុខឃើញមាត់ ។

ដារ៉ា ៖ ចឹងកាលហ្នឹងដឹងថាប្រុសស្រីហើយ?

ភាព ៖ បាទ!ដឹងថាស្រី យាយ ថែម គេហៅយាយទៅដឹងថាស្រី ។

ដារ៉ា ៖ ចុះមានដែលឮអ្នកដែលទទួលអង្ករពីពូនោះណាស នៅភ្នំលៀបនោះណាសមានឮគេនិយាយ ពីអត្តចរិក យាយ ថែម ទេដំនាន់ហ្នឹង?

ភាព ៖ ទេ! គេមិនដែលនិយាយប្រាប់ខ្ញុំ ខ្ញុំក៏មិនហ៊ានសួរគេដែរ អត្តចរិកគាត់នោះណាស់ ។

ដារ៉ា ៖ បាទ ។

ភាព ៖ ខ្ញុំក៏មិនបានសួរគេដែរ គេក៏ម្បិនដែលប្រាប់ខ្ញុំដែរ ខ្ញុំទៅដល់ទម្លាក់អង្ករឲ្យគេប្រាប់តែប៉ុននេះ ខ្ញុំត្រឡប់មកវិញហូបបាយអីរួច ត្រឡប់មកវិញយប់ បរទេះមកដល់យប់បានមកដល់ផ្ទះ ។

ដារ៉ា ៖ ពូមានបានឮរឿងឆ្លល់អីទេថា ស្រីធ្វើជាគណៈស្រុកអីចឹង ពេលពូត្រឡប់មកវិញអីមានធ្លាប់ ឮរឿងឆ្ងល់អីចឹងទេ?

ភាព ៖ ទេ មិនរឿងឆ្ងល់ទេ សម័យនោះសុទ្ធតែស្រីៗធ្វើតែធំមើលគ្រប់តែគ្នាក្រុមនិរតីនិរដាំងអី សុទ្ធតែស្រី ស្រីទាំងអស់ប្រុសនោះតិចណាស់ ។

ដានី ៖ ចឹងនៅពេលពូត្រឡប់មកវិញ ពូថាប្រធានភូមិឆែមនោះគេចាប់ដែរ?

ភាព ៖ បាទ!គេចាប់វ៉ៃចោលអស់ ។

ដានី ៖ គេចាប់វ៉ៃចោលហើយមាននរណាមកជំនួស?

ភាព ៖ មកជំនួសទៀតដូចជាអត់មានទេ ចាប់រួចពួកនិរតីគេមកក្រុមនិរតីមក និរតីមកមេភូមិគេអត់ ទាន់មានតែងតាំងអីទេណាស់ កំពង់តែចាប់វ៉ៃលុកវិជ្រួសច្របល់មិនទាន់តែងតាំងទេប្រធានភូមិ ទេ ដល់ត្រូវជិតវៀតណាមលាន់ឮមកនិរតីចូលមកបានមួយឆ្នាំ តែសុទ្ធតែស្រីៗមក ។

ដានី ៖ សុទ្ធស្រីៗ?

ភាព ៖ បាទ!ស្រីៗ ។

ដានី ៖ ចឹងកាលហ្នឹងអត់មានតែងតាំងប្រធានភូមិថ្មីទេ?

ភាព ៖ បាទ!មិនទាន់តែងតាំងអីទេ ។

ដានី ៖ ចឹងប្រធានឃុំ?

ភាព ៖ ប្រធានឃុំអត់ទាន់មានទេមានតែស្រីៗហ្នឹង គេហៅថានារីចលនាគ្រាន់មើលខុសត្រូវលើយើងតិចៗណាស់យើងក៏មិនសូវហ៊ានសំណេះសំណាលនិងគេឃើញមុខគេដើរមកយើងមិនសូវហ៊ានសួរនាំគេទេ ។ សម័យនោះយើងខ្លាចអំណាចគេដែរព្រោះគេនិយាយតែអីចឹងៗយើងមិនជាអ្នកខាងណាខាងណីយើងមិនហ៊ានជិតស្និតនិងគេមិនដូចយើងស្រុកស្រែគ្នាយើងណាស់ ។

ដានី ៖ ចុះពូកាលហ្នឹងក្រៅពីជីកអន្លូរ ក្រៅពីធ្វើស្រែហ្នឹងអត់មានធ្វើអីទៀតទេ?

ភាព ៖ អត់ទេ!អត់មានធ្វើអីទេខ្ញុំនៅធ្វើស្រែឡើងចប់ដល់វៀតណាមចូលខ្ញុំធ្វើតែស្រែអត់មានដែលបានទៅណាទៅណីទេ ។

ដានី ៖ ចឹងពូមានដែលឃើញមន្ទីរសន្តិសុខនៅភ្នំទ្រយោងទេ?

ភាព ៖ ទេ!មិនដែលឃើញទេ មិនដែលបានឃើញទេមានអ្នកណាហ៊ានចូលទេយើងប្រជាជនសាមញ្ញនោះ ។

ដានី ៖ នៅម្តុំណា?

ភាព ៖ មិនដឹងជាម្តុំណាខ្ញុំឮថាភ្នំទ្រយោងខ្ញុំមិនដែលឃើញទេ ឮគេថាទ្រយោងៗមិនដែលឃើញទេមិនដែលឃើញកន្លែងហ្នឹងទេ ។

ដារ៉ា ៖ កាលពីក្នុងបីឆ្នាំ៨ខែក្នុងសម័យខ្មែរក្រហមនិយាយរួមទៅពូមានបានឮឈ្មោះ ភ្នំទ្រយោងគុកភ្នំទ្រយោងទេ?

ភាព ៖ បាទ!ឮគេមិនមែនហៅគុកទេគេហៅកន្លែងសន្តិសុខ ។

ដារ៉ា ៖ សន្តិសុខ?

ភាព ៖ បាទ ។

ដារ៉ា : សន្តិសុខភ្នំទ្រយោង?

ភាព : បាទ ។

ដារ៉ា : ពាក្យតាមរយៈយ៉ាងម៉េចពូពាក្យ?

ភាព : ពាក្យតាមរយៈថា ដូចជាថាមេៗគេថា អ្នកណាធ្វើការមិនសមរម្យគេដកយកទៅលុតដុំ លត់ដុំ ដូចថាយើងមានការមិនសមរម្យអីហ្នឹង មានមាត់តូចមាត់ធំប្រកែកជាមួយគេកម្មាភិបាល ហ្នឹងណា ។អាហ្នឹងគេយកទៅលត់ដុំយើងពាក្យថាទៅនោះខ្លាចរៀងខ្លួនទំប្រឹងធ្វើការគ្រប់ៗគ្នា ។

ដារ៉ា : ចឹងមានន័យថា ពូបានពាក្យភ្នំទ្រយោងហ្នឹងតាំងពីសម័យហ្នឹងមក?

ភាព : បាទ!សម័យហ្នឹង យាយ ថែម ហ្នឹងឯង ។

ដានី : ចឹងមានពាក្យថាប្រធានគេឈ្មោះអីដែរនៅភ្នំទ្រយោងហ្នឹង?

ភាព : ទេ!អត់ដឹងទេខ្ញុំស្គាល់តែយាយថែមមួយប៉ុណ្ណោះ កន្លែងសន្តិសុខនោះមិនដឹងថាប្រធានគេ ឈ្មោះអីៗអត់ដឹងទេ ។

ដារ៉ា : ក្នុងភូមិពូរស់នៅកាលសម័យបីឆ្នាំហ្នឹងណាស់ សម័យខ្មែរក្រហមហ្នឹងមានសមាជិកក្នុងភូមិឬ ក៏ជាមិត្តភក្តិពូអ្នកជិតខាងពូអីត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅភ្នំទ្រយោងដែរពូ?

ភាព : ទេ!អត់មានទេ ម៉្លុំខ្ញុំអត់មានទេភូមិខ្ញុំអត់មានបញ្ជូនទៅទេ មានដល់ភ័យខ្លាំងអាចុងបញ្ចប់ ចូលសៀមអស់ ដែលគេរឹបខ្លាំងគេវៃប្រធានភូមិអីហ្នឹងរត់ទៅម៉ត់នៅតែខ្ញុំកូនខ្ចីរត់ទៅមិន រួចចោលកូន ។

ដារ៉ា : ចឹងគ្រួសារពូដែលស្លាប់កាលសម័យហ្នឹងដោយសារអីពូ?

ភាព : ដោយសារអត់បាយហ្នឹងឯង ស្ងោត្រួយដំឡូងស្ងោត្រួយឈើស្លឹកណាដែលយើងហូបកើត ទៅប្រឡូកប្រឡល់គ្នាទៅទាស់ ។

ដារ៉ា : អូ!ទាស់?

ភាព : បាទ!ទាស់កូនពីរខែ ។

ដារ៉ា : ហើយកូនរាល់ថ្ងៃនៅរស់ដែលពូ?

ភាព : បាទ!នៅរស់ ។

ដារ៉ា : ចឹង?

ភាព : បាទ!បានប្តីបានប្រពន្ធហើយអស់ហើយ ។

ដារ៉ា ៖ កូនគ្រួសារមុនហ្នឹង?

ភាព ៖ បាទ ។

ដារ៉ា ៖ ស្រីឬប្រុសពូ?

ភាព ៖ ស្រី១ ប្រុស១ ។

ដារ៉ា ៖ ចឹងបានរៀបចំគ្រួសារអស់ហើយ?

ភាព ៖ បាទ!រៀបចំអស់ហើយ បានកូនម្នាក់ពីរម្នាក់បីហើយ ។

ដារ៉ា ៖ ចេះអាចចិញ្ចឹមរស់មកដល់ឥឡូវដែរ?

ភាព ៖ អូរ!ចិញ្ចឹមកូនតាំងពីពីរខែនោះអូស!លំបាកណាស់ កាលនោះម្ដាយខ្ញុំមិនទាន់ស្លាប់ ។ ដល់ម្ដាយខ្ញុំមិនទាន់ស្លាប់ក៏លួចដំឡូងមីប៉ុននេះមកចំហុយឲ្យចៅទៅ ប្រចាប់លាយបបរតិចៗ ដែលគេឲ្យរបបមនុស្សគេឲ្យរបបកន្ទះកំប៉ុង កន្ទះកំប៉ុងខ្ញុំមិនហ៊ានប៉ះពាល់ខ្ញុំដើមប្រលិតដើមត្រកួនហាន់ទៅដាក់ស្ងោហូបទៅពីដើមមិនថារស់ទេដែលហូបហ្នឹង អំបិលក៏មិនមានទៀត ។ ខ្ញុំហូបស្រូវនៅក៏មានដែរ ។ ពេលប្រូតអីចឹងស្រូវថ្មីចាប់បូតហូប ។

ដារ៉ា ៖ ចឹងកូនដែលថាពីរខែហ្នឹងអាចរស់មកដល់ឥឡូវ?

ភាព ៖ បាទ!រស់មកដល់ឥឡូវ ។

ដារ៉ា ៖ បានគ្រួសារអី?

ភាព ៖ បាទ!បានគ្រួសារបានកូន១ហើយ ។

ដានី ៖ បាទ!ចឹងពេលបែកឆ្នាំ៧៩ហើយហ្នឹងពូអត់មានរត់ទៅណាទេ?

ភាព ៖ បាទ!អត់មានរត់ទៅណាទេ ចូលមកភូមិកំណើតនេះបណ្ដោយចេញពីជើងភ្នំមកចូលមកភូមិកំណើតខ្លួនឯងវិញ ខ្ញុំនៅភូមិកំណើតប៉ុស្តិ៍ចាស់ អានេះខ្ញុំទើបចេញមកនៅនេះ៥ឆ្នាំ ។

ដានី ៖ តែអានេះក៏ភូមិប៉ុស្តិ៍ចាស់ដែរ?

ភាព ៖ បាទ!អានេះក៏ប៉ុស្តិ៍ចាស់ដែរ នោះវាចង្អៀតពេក ។

ដានី ៖ បាទ!លោកពូពួកខ្ញុំដូចជាអស់សំនួរអី សួរនាំលោកពូទៀតហើយ ។

ភាព ៖ បាទ ។

ដានី ៖ ចឹងខ្ញុំអរគុណពូច្រើន ។

ភាព ៖ បាទៗ ។

«ចប់»